# ការសំភាស៍របស់បងស្រីនួន យ៉ា

កះ អ្នកដែលត្រូវសំភាស៍គេកញ្ញា អ៊ុំ ធីដា ខះ អ្នកដែលអោយគេនិងសំភាស៍ នួន យ៉ា

កះ
ខ្ញុំសូមថ្លែងអំណរគុណដល់បងដែលបងអោយខ្ញុំធ្វើការសំភាស៍បងហើយការសីភាសនេះគឺធ្វើដោយសកលវិទ្យាល័យBYUហើយដោយសារតែសកលវិទ្យាល័យនិងចង់ថៃរក្សាជីវះប្រវិត្តរបស់ជីដូនជីតារបស់បងហើយទុកអោយកូនចៅជំនាន់ក្រោយនិងគេបានមើលបានស្គាល់និងបានដឹងពីជីវប្រវិត្តរបស់បងបន្ទាប់ពីធ្វើការសំភាស៍និងរួចហើយតើបងអាចអោយខ្ញុំនិងដាក់ការសំភាស៍និងទៅក្នុងប្រពន្ធ័វើកផ្សាយរបស់សកលវិទ្យាល័យនិងបានទេបង?

ខះ បាន។

កះ ហើយខ្ញុំជាអ្នកសំភាស៍មានឈ្មោះថាអ៊ុំ ធីដាហើយធ្វើឡើងនៅថ្ងៃទី 31 ខែ 01 ឆ្នាំ 2018 ទីកន្លែងគឺនៅភូមិឬស្សី សង្កាត់មានជ័យ ខណ្ឌមានជ័យ
រាជធាន៏ភ្នំពេញ។ហើយខ្ញុំសូមសួរបងបញ្ជាក់បានទេថាតើខ្ញុំអាចដាក់ការសំភាស៍និងទៅក្នុងប្រពន្ធ័វើកផ្សាយនិងបានដែលទេបង?

ខះ ចាបានអូន។

កះ ចាខ្ញុំសូមសួរបងថាតើបងមាននាមត្រគោលអ្វីដែលបង?

ខះ នួន យ៉ា។

កះ នួន យ៉ា។អញ្ចឹងតើបងមានឈ្មោះហៅក្រៅដែលទេបង?

ខះ អត់មានទេ។

កះ ដូចជាឈ្មោះហៅពីក្នុងអីមានដែលទេបង?

ខះ អត់មានទេ។

កះ ចាអរគុណច្រើនបង។ តើក្នុងឆ្នាំនេះតើបងមានអាយុប៉ុន្មានដែលបង?

ខះ 39។

កះ អញ្ចឹងតើបងមានចាំថាបងកើតនៅក្នុងឆ្នាំណាខែណាដែលទេបង។

ខះ អត់ចាំបងកាលនៅតូចនិង។

កៈ អញ្ចឹងតើបងប្រហែលថាបងកើតនៅក្នុងឆ្នាំណាដែលបង?

ខៈ នៅឆ្នាំ79។

កៈ នៅឆ្នាំ79។ហើយចុះចំនែក។

ខៈ ខែថ្ងៃវិញបងអត់ចាំទេ។។

កៈ ឪពុកម្ដាយវិញបង?

ខៈ ពុកម៉ែក៏អត់ចាំដែល។

កៈ
ហើយចុះក្នុងឆ្នាំច័ន្ទគិតវិញតើបងកើតនៅក្នុងឆ្នាំអ្វីដែលបង?ដូចជាឆ្នាំជូតឆ្នាំថោះអីអញ្ចឹង។

ខៈ កើតនៅឆ្នាំមមែ។

កៈ ឆ្នាំ មមែ។ ឆ្នាំមែមស្វតអី។

ខៈ គិតទៅថា39ចូលសែបសិបអីហើយ។

កៈ ចាឆ្នាំមមែគឺស្វតពពែ។

ខៈ ស្វតពពែ។

កៈ និងហើយហើយទីកន្លែងកំណើតតើបងកើតនៅកន្លែងណាដែលបង?

ខៈ កើតនៅស្វាយរៀង។

កៈ នៅស្វាយរៀងនិងតើភូមិឃុំអីដែលទៅបង?

ខៈ ភូមិតស្វាយ ឃុំ សំលី ស្រុកមង្គល។

កៈ ចាអញ្ចឹងតើបងមានបងប្អូនប៉ុន្មាននាក់ដែលបង?

ខៈ បងប្អូនគឺអឺនៅសល់បួននាក់ស្លាប់អស់ពីរនាក់នៅពលពតអស់ពីរនាក់។

កៈ ចាអញ្ចឹងខ្ញុំសូមកាត់បងបន្តិចតើពួកកាត់និងស្លាប់ដោយសារអ្វីដែលបង?

ខៈ
ស្លាប់ដោយសារតែពលពតនិងដេញបាញ់និងមួយហើយដោយសារតែត្រូវថ្នាក់ពលនិងមួយ។

កៈ អូមូលហេតុអ្វីបានជាគាត់និងត្រូវថ្នាក់ពលអញ្ចឹងបង?

ខ៖
គាត់ទៅរ៉ែងរែកនៅប៉ៃលិនកាលនិងខ្ញុំនៅតូចដែលលឺគេថាដាក់ថ្នាក់ហើយគេយកមកដាក់ចោល។

ក៖ ពេលស្លាប់និងបងអត់។

ខ៖ ពេលស្លាប់និងអត់ឃើញសាកស្ពទេ។

ក៖ ចុះស្ព....?

ខ៖
គ្រាន់តែអ្នកនៅកន្លែងនោះនិងគេមកនិយាយប្រាប់យើងថាគាត់ស្លាប់អីអញ្ចឹងគេបានផ្តល់ដំណឹងអោយយើអអីញ្ចឹង៕

ក៖
ប៉ុន្តែអត់បានយកសាកស្ពគាត់និងមកធ្វើពីធីអ្វីទេហើយតើបងជាកូនទីប៉ុន្មានដែលបង?

ខ៖ បងជាកូនទីបួន។

ក៖ កូនទីបួនដូចជាខ្ញុំដែលនិង?ហើយតើបងប្អូនរបស់បងមានឈ្មោះអ្វីដែលទៅបង?

ខ៖ ចានាក់នៅគឺ ឈ្មោះថា ឈ្មោះយ៉ា ឈ្មោះថវ៉ានិងឈ្មោះ ថាវ៉ាន់។

ក៖
តើបងមាននៅចង់ចាំសាច់រឿងអ្វីខ្លះដែលទាក់ទង់និងបងប្អូនរបស់បងការពីបងនៅពីក្មេងៗអីអញ្ចឹងបងដែលបងចូលចិត្តលេងជាមួយនិងពួកគាត់?

ខ៖ ធ្លាប់លេងលោតស៊ូលេងអាប៉ាងកាស៊ូចូលក្នុងវល់។

ក៖
និងខ្ញុំចូលចិត្តលេងអាមួយនិងដែលនិង។ពេលដែលបងនៅពីក្មេងតើបងចូលចិត្តធ្វើខ្លះជាមួយនិងពួកគាត់ដែលជាបងប្អូនរបស់បង?

ខ៖ ខ្ញុំចូលចិត្តលេងម៉ាឡុកបីឡ៍ហើយលូកយកដីឥដ្ឋអីនិងមកលេង។

ក៖ ហើយពេលនិងតើពួកគាត់រស់នៅកន្លែងណាហើយពួកគាត់កំពុងធ្វើអ្វីដែលបង?

ខ៖ បងប្អូនខ្ញុំនិងមែន?

ក៖ ចាបង។

ខ៖
គាត់នៅស្រុកមួយនាក់ធ្វើការងាររោងចក្រម្នាក់ទៀតនៅស្រុកប្ដីគាត់ធ្វើការងាររោងចក្រអីដែលហើយចំនែកខ្ញុំនិងវីញគឺនៅកន្លែងនិងនៅជាមួយនិងអង្គអីនិង?

ក៖ ដូចជាពួកគាត់និងរស់នៅស្រុកណាអីដែលហើយបង?

ខ៖ គាត់នៅស្វាយរៀងនិងមួយនិងនៅកៀនស្វាយនិងមួយ។

ក ចុះឪពុកម្ដាយរបស់បងតើពួកគាត់ាមានឈ្មោះអ្វីខ្លះដែលទៅបង?

ខ៖ គាត់មានឈ្មោះថា នួន យ៉ាន់ តូចអឿរ។

ក៖ ដូចជាប៉ារបស់មានឈ្មោះអ្វីដែលបង?

ខ៖ នួន យ៉ាន់ ។

ក៖ ហើយចុះម្ដាយវិញតើគាត់មានឈ្មោះអ្វីដែលទៅបង?

ខ៖ គាត់ឈ្មោះថា តូចអឿរ។

ក៖ ចាអញ្ចឹងតើ ពួកគាត់និងមានអាយុប៉ុន្មានហើយបង?

ខ៖ គាត់ស្លាប់យូរហើយពេលដែលគាត់និងស្លាប់និងគឺគាត់មានអាយុ 60ឆ្នាំ។

ក៖ ពួកគាត់ស្លាប់ទាំងពីឬក៏នៅមួយបង?

ខ៖ នៅម្ដាយ។ដែលគាត់អាយុ73ឆ្នាំហើយ.

ក៖ ចឹងតើបងមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ពួកគាត់ដែលទេបង?

ខ៖ អត់ចាំទេ។

ក៖ ចុះឆ្នាំច័ន្ទគិតវិញតើពួកគាត់និងកើតនៅឆ្នាំណាដែលបង?

ខ៖ ម្ដាយដូចជាឆ្នាំជូតហើយឪពុកគឺឆ្នាំមមែ។

ក៖ តើបងមានចាំទីកន្លែងដែលពួកគាត់និងកើតដែលទេបង?

ខ៖ អត់ចំទេ។

ក៖ ដូចជានៅភូមិណាទីកន្លែងណាអីអញ្ចឹងបង?

ខ៖
អត់ដឹងរស់នៅតែទេព្រោះអីពេលដែលរស់ជាមួយនិងពួកគាត់រត់នៅតែពេញនិងពីស្រុកមួយទៅស្រុកមួយអញ្ចឹងហើយអត់ដែលឬគាត់និងនិយាយថាគាត់ទៅស្រុកណាអីទេ។

ក៖ ហើយតើគាត់និងរកអ្វីដើម្បីចិញ្ចឹងជីវិតដែលបង?

ខ៖ គាត់ធ្វើស្រែចាំករអីនិង។

ក៖ ហើយតើគាត់ជាមនុស្សយ៉ាងមិចដែលបង?

ខ៖ គាត់ស្លូតដែលតែកាច់ក្នុងគ្រួសារ។

ក៖ អញ្ចឹងបងពីបងធ្វើអីខុសមែនទើបគាត់កាចឬក៏គាត់ចេះតែកាចអញ្ចឹងទៅ?

ខ៖ អត់ទេគាត់កាចតែក្នុងគ្រួសារទេ។

ក៖ ចុះម្ដាយរបស់បងស្រិវិញតើគាត់និងធ្វើអ្វីសម្រាប់ប្រកបរបរចិញ្ចឹមជីវិតដែលបង?

ខ៖ គាត់ធ្វើស្រែដែលនិង។

ក៖
អញ្ចឹងមានន័យថាគាត់ធ្វើស្រែទាំងពីនាក់សម្រាប់ចិញ្ចឹងជីវិតហើយតើម្ដាយរបស់បងគាត់ជាមនុស្សយ៉ាងមិចដែលបង?

ខ៖ គាត់ស្លូត។

ក៖ តើបងមាននៅចាំសាច់រឿងអីដែលបងនៅតូចៗជាមួយនិងពួកគាត់ដែលទេបង?

ខ៖ ដូចជាអត់នៅជុំគ្នាអីនិងស្និតថ្លែរអីផងនិង។
គាត់ទៅចោលបាត់ៗនៅតែជាមួយនិងម្ដាយអីនិង។

ក៖ ហើយចុះបងចាំអ្វីខ្លះជាមួយនិងគាត់ដែលបង?

ខ៖ នៅផ្ទះជួលធ្វើស្រែអោយគាត់អីអញ្ចឹងនិង។

ក៖
ហើយអញ្ចឹងតើគាត់មានដែលាប្រាប់បងពីប្រវិត្តគាត់ដល់បងអត់ពេលដែលបងនៅពីក្មេងបង?ជីវិតគាត់ដែលលំបាកអីអញ្ចឹងបងហើយជាពិសេសទៀតនិងគឺជំនាន់ពលពតអីអញ្ចឹងបង?

ខ៖ ធ្លាប់ប្រាប់។

កៈ
និងហើយតើក្នុងជំនាន់និងតើមានការលំបាកនិងការតស៊ូអ្វីខ្លះអត់ឃ្លានិងយ៉ាងមិចខ្លះអីអញ្ជឹងបង?

ខៈ
គាត់និយាយថាបរបេវិញបានតែមួយវែកទេហើយស្រូវធ្វើបានល្អណាស់តែអត់បានហូបខ្លួនឯងទេហើយគេអោយទៅរ៉េងអង្ករអីអញ្ចឹងទៅគាត់លួចយកមួយក្តាប់ៗអីអញ្ចឹងទៅដាក់នៅក្នុងថង់សំពតអីអញ្ជឹងយើងមកដាំបរបអោយកូនពេលខ្លះអញ្ជឹងទៅគាត់ដាំបាយគាត់ដាក់ក្នុងថង់សំពតហើយគាត់លួចយកមកអោយកូនអីអញ្ជឹងដែលទៅគាត់ធ្លាប់និយាយអញ្ជឹងហើយពួកគាត់និងអត់មានអីនិងញ៉ាំទេ។

កៈ
អញ្ជឹងតើបងមាននៅចាំឈ្មោះជីដូននិងជីតារបស់ដែលទេបង?ឈ្មោះជីដូនជីតាខាងម្តាយបងមាននៅចាំអត់ថាតើពួកគាត់និងមានឈ្មោះអ្វីខ្លះដែលបង?

ខៈ ដូចជាអត់ចាំទេអូចាំមួយដែលគាត់ឈ្មោះថាយាយ
អ៊ិនតែត្រគោលគាត់និងអត់ស្គាល់នោះទេ។

កៈ គាត់ឈ្មោះថាយាយអ៊ិនគាត់ខាងម្តាយឬខាងឪពុកបង?

ខៈ ខាងម្តាយ។

កៈ ចុះខាងឪពុកវិញបង។តើគាត់មានឈ្មោះអ្វីវិញបង?

ខៈ ឈ្មោះតាគាត់ឈ្មោះថាតាម៉ៅ។

កៈ តើបងមានដឹងថាតើពួកគាត់និងកើតនៅក្នុងខែណាអីដែលទេបង?

ខៈ ដូចជាអត់ដឹងផងនិង។

កៈ ហើយតើពួកគាត់ស្លាប់ក្នុងឆ្នាំណាតើបងមាននៅចាំអត់បង?

ខៈ ខាងម្តាយនិងគឺសម្លាប់ខាងពលពតនិងតា។
ហើយខាងឪពុកនោះដែលស្លាប់នៅពលពតនិងគឺយាយដល់ពេលគាត់ស្លាប់បែកពីអាពលពតនិងហើយបានយាយ។

កៈ
តើបងមានបានដឹងថាមូលហេតុបានជាពួកគាត់ស្លប់នៅជំនាន់ពលពតតើបងមានដឹងខ្លះដែរទេបង?

ខ៖ បើយាយហើយនិងតាខ្ញុំអត់ដឹងទេ។

ក៖
អរគុណច្រើនបងហើយខ្ញុំសូមសួរបងបន្តទៀតបងថាតើគ្រួសាររបស់មករស់នៅទីក្រុងភ្នំពេញឬក៏នៅតែរបស់នៅខេត្តអីអញ្ចឹងបង?

ខ៖ ខ្ញុំរត់ចេញពីស្រុកមកនៅទីក្រុងភ្នំពេញនិងជិតដប់ឆ្នាំហើយ។

ក៖ មូលហេតុអ្វិបានជាបងចេញពីស្រុកមករស់នៅទីក្រុងភ្នំពេញវិញអញ្ចឹងបង?

ខ៖
មូលហេតុនិងគឺនៅជាមួយនិងឪពុកម្តាយនិងពិបាកអញ្ចឹងអត់មានអីហូបនិយាយរួមទៅខ្វះមួយចប់អញ្ចឹងពិបាករស់នៅខ្ញុំក៏រត់ចេញមកភ្នំពេញនិងរស់នៅម្នាក់ឯងអីអញ្ចឹងហើយពេលដែលនៅដំបូងគឺនៅផ្ទះជាមួយនិងគេទេ
បន្ទាប់មកបានរកធ្វើការងាររោងចក្រដល់ពេលដែលធ្វើការងាររោងចក្រអីអញ្ចឹទៅខ្ញុំក៏ស្គាល់គេអីអញ្ចឹងទៅក៏ជួលផ្ទះគេនៅខ្លួនឯងអីអញ្ចឹងទៅ។

ក៖ ចុះអញ្ចឹងតើបងមានបងប្អូនដែលរស់នៅក្រៅប្រទេសដែលទេបង។

ខ៖ អត់មានទេ។

ក៖ តើបងបានរៀនអាពាហ៍ពិពាហ៍ហើយនៅបង?

ខ៖ ហើយហើយ។

ក៖ ហើយឪឡូវនិងមានកូនប៉ុន្មាននាក់ដែលបង?

ខ៖ មានចំនួន3នាក់។

ក៖ ហើយចុះប្តីរបស់បងនិងតើគាត់មានឈ្មោះអ្វីដែលបង?

ខ៖ គាត់ឈ្មោះថានឹម សារឿន។

ក៖ ចុះគាត់មានឈ្មោះហៅក្រៅដែលទេបង?

ខ៖ អត់ផងនិង។

ក៖ តើអាពាហ៏ពិពាហ៍របស់បងនិងតើបងរៀបការហើយនឆ្នាំណាខែណាដែលបង?

ខ៖ 2014។

ក៖ 2014។

ខ៖ និងហើយ។

ក៖ អញ្ចឹងប៉ុន្តែប៉ុន្មានឆ្នាំនិងដែលនិង។

ខ៖ និងហើយ។

ក៖ ថ្ងៃខែអីតើបងមានចាំអត់បង។

ខ៖ អត់ចាំទេតែពេលដែលកាលនិងនៅឆ្នាំ2004។

ក៖ ខែថ្ងៃដែលទេបង?

ខ៖ អត់ចាំទេ

ក៖ អាពាហ៌ពិពាហ៌របស់បងរៀបការដោយខ្លួនបងនិងស្វាមីរបស់បងឬក៏ចាស់ទុំគេរៀបចំអីអោយអញ្ចឹងបង?

ខ៖ ចាស់ទុំរៀបចំអោយអញ្ចឹង។

ក៖ តើចំនួននិងមានថ្លៃជំនួនដែលទេបង?

ខ៖ មាន។

ក៖ ជំនួននិងថ្លៃប៉ុន្មានដែលបង។

ខ៖ 200ដុល្លា.

ក៖ អញ្ចឹងតើបងអាចប្រាប់ខ្ញុំបានទេពីដំបូងដែលបងបានជាមួយនិងប្តីរបស់បងបានដែលទេបង។

ខ៖ ជួបនៅពេលដែលធ្វើការងាររោងចក្រអីអញ្ចឹងជួបគ្នានៅរោងចក្រដល់មួយឆ្នាំបានស្រលាញ់គ្នាគាត់មកតាមស្រលាញ់ខ្ញុំអញ្ចឹងតែខ្ញុំអត់ស្រលាញ់ទេព្រោះពេលនិងខ្ញុំគិតថាអត់ចង់បានគ្រួសារអីនោះទេហើយពេលនិងក៏គិតថាលេងបានរៀងសូត្រអីហើយក៏គាត់និងទៅសួរដល់ម៉ែឪអញ្ចឹងទៅ។

ក៖ អញ្ចឹងដំបូងឡើយប្តីរបស់បងនិងគឺតាមស្រលាញ់បង។អញ្ចឹងតើបងចេះអានភាសាខ្មែរនិងបានល្អអីដែលទេបង?

ខ៖ ចេះអានចេះ។

ក៖ ចេះអានចេះសរសេរ?

ខ៖ អាសរសេរនិងដូចជាមិនសូវប៉ុន្មាននោះទេ។

ក៖ ចុះអញ្ចឹងតើបងចេះភាសាផ្សេងទៀតដែលទេបង?

ខ៖ ភាសាអង់គ្លេងភាសាចិនអីអញ្ចឹងបង?

ក៖ តើបងបានរៀនកំរិតថ្នាក់មួយណាដែលបង?

ខ៖ ខ្ញុំរៀនដល់ថ្នាក់ទីដប់មួយ។

ក៖ បងរៀនដល់កំរិតវិទ្យាល័យហើយ។ ចុះបងរៀននៅសាលាណាដែលបង?

ខ៖ អត់មានសាលាតែម្តងបើមានក៏បាក់បែកអស់ដែលមានតែរៀននៅវត្តអីនោះទេ?

ក៖ ហើយសាលាមួយនិងតើគេហៅឈ្មោះអ្វីដែលបង?

ខ៖ ដល់ពេលមកអនុវិទ្យាល័យនិងគេហៅថាអនុវិទ្យាល័យកំពង់រោទ៍។

ក៖ តើបងមានមិត្តដែលស្និតស្នាអីជាមួយនិងគ្នាអីដែលទេបង?

ខ៖ ដូចជាអត់មានទេ។

ក៖ មួយនាក់ពីរនាក់ដែលធ្លាប់និយាយជាមួយនិងគ្នាពេលដែលរៀនអីដែលទេបង?

ខ៖
ម្នាក់ពីរនាក់អីមានតែក្នុងចំណោមភូមិរបស់ខ្ញុំនិងមានស្រីតែខ្ញុំព្រោះពួកគាត់និងនៅស្រុកឆ្ងាយមករៀននៅកន្លែងនិង។

ក៖ ហើយតើមិត្តភក្តិស្និតស្នារបស់បងនិងតើមានឈ្មោះអ្វីដែលទៅបង?

ខ៖ ឈ្មោះនៀត សាវ៉ាន់ ហៅក្រៅឈ្មោះថាម៉ៅ។

ក៖ ហើយម្នាក់ទៀត?ឬក៏មានតែគាត់ទេ?

ខ៖ មិត្តភក្តិស្រីនៅភូមិនោះគឺឈ្មោះថាសារុំតែមិនដឹងថាអីសារុំ។

ក៖ និងគ្រាន់តែដឹងថាឈ្មោះសារុំៗ។

ខ៖ ចាចា។

កៈ
តើបងមានចង់ចាំបានរឿងអ្វីខ្លះទាក់ទងនិងពួកគាត់ឬក៏សកម្មភាពអីដែលបងចង់ចាំអីជាមួយនិងគាត់ដែលទេបង?

ខ.	ពេលគឺខំតែរៀនទេម្នាក់ៗអីចេះស្រលាញ់គ្នាទេ។

កៈ ចុះមានធ្លាប់ចែកបាយគ្នាញ៉ាំអីដែលទេបង?

ខៈ
និងវិចបាយយកទៅញ៉ាំនៅសាលានិងដល់ល្ងាចហើយពេលខ្លះដំាបាយអេចយកទៅគ្នាខោអាវអីនិងស្លៀកទៀតហើយអត់មានកង់ជិះទៅបានឆឈប់រៀនអីអញ្ចឹងទៅខ្ញុំបើដូចឥឡូវនិងខ្ញុំរៀនចេះណាស់ណាជំនាន់និងបើដូចជាឥឡូវវិញដឹងតែបានល្អតែម្តងតែអត់ទេគ្រូមានតិចហើយរៀនខានរៀនខានហើយអាអត់មានសាលារៀននិងផងពេលអាចូលទៅបឋមរៀនលើវត្តឡើងលើកុតលោកទៅរៀនដល់ពេលដែលច្រុះខ្មៅដៃអីមួយអញ្ចឹងទៅសុទ្ធតែមករើនៅក្រោមតែមិនដូចឥឡូវមានគ្រូមានអីនិងបង្រៀនអីអញ្ចឹងបើការនិងវិញមិនបាច់ទេតស៊ូរៀនតាំងថ្នាក់ទីដប់មួយចូលដល់ថ្នាក់ទីដប់ទីអីដែលហើយដល់ពេលពិបាកពេកទៅក៏រត់មកភ្នំពេញវិញ។

កៈ អញ្ចឹងខ្ញុំសូមសួរបងតទៅថទៀតតើបងមានធ្លាប់ធ្វើការងារវាលស្រែដែលទេបង?

ខៈ ធ្លាប់ធ្លាប់ធ្វើភ្ជួរដី។

កៈ ស្ទុង់ ។

ខៈ ស្ទុង់
បោកស្រូវបោកអីនិងទេមែនបោកស្រូវអីនិងទេតែគេហៅថាប៉ែនស្រូវអីនិងវិញបុកស្រូវហើយពេលបុកជំនាន់និងគេយើងក្បាល់យើងនិងមកបុកវាអត់មានម៉ាស៊ីនអីនោះទេ?

កៈ បុកក្បាល់អោយវាចេញជាអង្ករ។

ខៈ ចានិងហើយហើយពេលខ្លះងើបតាំងពីម៉ោងបួនមកម្លេស។

កៈ អញ្ចឹងការធ្វើការមួយនិងតើហាត់ដែលទេអ្នកមីង?

ខៈ
ឡើងបែបដៃនិងបែបជើងហើយពេលដែលទៅធ្វើស្រូវវិញគឺនៅហាដៅអីនិងវិលល្ងាចបានត្រលប់មកផ្ទះវីញពិបាកណាស់ជំនាន់និង?

កៈ អញ្ចឹងបងធ្លាប់ធ្វើការងារអ្វីខ្លះនៅក្នុងជីវិតរបស់បង?

ខ៖ ខ្ញុំមែន?

ក៖ ចាចាបង។

ខ៖ ធ្វើស្រែ ធ្វើស្រូវនៅតាមវាលស្រែនិងចំការ ហើយបន្ទាប់មកគឺបានមករត់មកនៅភ្នំពេញវិញម្នាក់ឯងទៅនៅជាមួយនិងគេទៅនៅផ្ទះគេ ហើយទៅធ្វើការងាររោងចក្រហើយបានចេញមកជួលផ្ទះខ្លួនឯងរហូតដល់មកពិបាកអីអញ្ចឹងទៅបានមកនៅជាមួយនិងអង្គារអីអញ្ចឹទៅអង្គារនិងគេធ្វើផ្ទះអីនិងអោយនៅធ្វើដល់រាល់ថ្ងៃនិងទៅ។

ក៖ តើមកដល់ពេលនេះតើជីវិតរបស់បងបានផ្លាស់ប្តូរអ្វីខ្លះដែលទៅបង?ដូចជាបងឃើញថាបងមានភាពរីកចំរើនអ្វីខ្លះដែលបង?

ខ៖ គ្រាន់ថាខ្ញុំឥឡូវរោងធូរជាងពីរមុនហើយការរស់នៅរបស់ខ្ញុំវាអត់សូវពិបាកដូចមុនអីអញ្ចឹងយើងអាចរកអីដោយខ្លួនឯងអញ្ចឹងមានពេលសរាកហើយខ្ញុំចេះធ្វើការងារ។

ក៖ អរគុណបងហើយតើម្ហូបដែលអ្នកមីងចូលចិត្តអ្វីជាងគេអ្នកមីង?

ខ៖ សម្លរឆាប់ឆៃយ។

ក៖ អញ្ចឹងបងចូលចិត្តសំម្លរទឹក។

ខ៖ ចូលចិត្តសម្លរទឹកនិងបន្លែអញ្ចឹង។

ក៖ អញ្ចឹងតើបងចូលចិត្តល្បែងប្រជាប្រែយណាខ្លះដែលទៅបង។ដូចជាបោះអង្គុន់ បោះឈូក ទាញព្រាត់អញ្ចឹងបង?

ខ៖ បោះអង្គុន់ អីនិង។

ក៖ បងលេងល្បែងនិងពេលដែលបងនៅក្មេងឬក៏ពេលដែលបងមានគ្រួសារហើយបងនៅតែលេងវាទៀតបង?

ខ៖ ពេលបងនៅពីក្មេងបងលេងវាដល់ពេលធំហើយបងអត់ដែលលេងអីទេ?

ក៖ ចាអរគុណច្រើនបងតើចំរៀងណាដែលបងចូលចិត្តស្តាប់ជាងគេដែលបង?

ខ៖ ខ្ញុំចូលចិត្តតែស្តាប់បទណាមួយដែលកំសត់ៗ។

កៈ តើបទដែលបងចូលចិត្តស្ដាប់និងមានចំណងជើងអ្វីដែលបង?

ខៈ
ខ្ញុំអត់ចាំចំណងជើងអីនិងទេតែខ្ញុំចាំអ្នកចំរៀងដែលខ្ញុំចូលតចិត្តស្ដាប់និងគឺអ្នកមីងមេងកែវពេជ្រចិន្ដាតែខ្ញុំអត់ស្គាល់ចំនងជើងបទចំរៀងនិងទេ។

កៈ
ចាអញ្ចឹងខ្ញុំចង់សួរបងមួយទៀតដែលប្រសិនបងអត់ស្គាល់ចំនងជើងអញ្ចឹងតើបងអាចច្រៀងបានទេបង?

ខៈ អត់ផងនិង។

កៈ តើបងមានបងប្អូនណាមួយដែលចេះលេងឧបករណ៏ភ្លេងដែលទេបង?

ខៈ អត់មានទេ។

កៈ ចុះខាងប្ដីរបស់បងវិញ?

ខៈ ក៏អត់មានដែល។

កៈ ហើយចុះផ្ទះរបស់បងមានលក្ខណះយ៉ាងមិចដែលបង?ដូចជាធ្វើពីអ្វីអញ្ចឹងបង?

ខៈ ផ្ទះពីមុនផ្ទះប្រក់ស្បូវ។

កៈ ធម្មតានៅខេត្ត។

ខៈ ចានិងហើយ។

កៈ ហើយចុះពេលអ្នកមីងមកនៅផ្ទះអង្គការនិងតើមានលក្ខណះមិចដែលអ្នកមីង?

ខៈ ឈើនិងសង្ក័។

កៈ
តើផ្ទះមួយនិងតើបងមានជួយអង្គការធ្វើដែលទេបងឬក៏ពេលដែលគេធ្វើហើយបានបងមកនៅ?

ខៈ ពេលគេធ្វើហើយបានបងទៅនៅ។

កៈ
ចាអរគុណច្រើនបងតើបងមានជំនាញណាដែលបន្តវេនពីគ្រួសារដែលទេដូចជាធ្វើនំធ្វើអីអញ្ចឹង?

ខ៖ ខ្ញុំចេះត្បាញកន្ទេរដែល។

ក៖ បងចេះត្បាញ់កន្ទេរហើយបងចេះគ្រប់ម៉ូតូតែម្ដងមែនបង?

ខ៖ ចេះដាក់ពណ៌ដាក់អីអញ្ចឹង។

ក៖ ចាចុះជំនាញធ្វើនំធ្វើអីបងអត់ចេះទេ?

ខ៖ អត់ចេះទេ។

ក៖
តើបងអាចប្រាប់ខ្ញុំបានទេអំពីការលំបាករបស់បងបានទេបងថាបងបានជួបជាមួយនិងការលំបាកអ្វីខ្លះដែលបង?

ខ៖ ចំពោះខ្ញុំគឺលំបាកតាំងពីតូចមកម្ល៉េះរហូតមកដល់ពេលឥឡូវនៅតែពិបាក។

ក៖ តើការពិបាករបស់បងមានការលំបាកអ្វីខ្លះដែលបង។

ខ៖ ជួបជាមួយនិងបញ្ហាផ្លូវកាយនិងផ្លូវចិត្តរហូតដល់ឥឡូវនេះ
តែឥឡូវផ្លូវកាយនិងលេងហើយនៅតែមានផ្លូវចិត្តដល់សព្វថ្ងៃ។អញ្ចឹងជីវិតរបស់ខ្ញុំនៅតែទទួលការរង់គ្រោះផ្លូវចិត្តយ៉ាងខ្លាំងចំពោះរូបខ្ញុំពីព្រោះជីវភាពពីមុនគឺខ្ញុំពីបាកក្នុងគ្រួសារដល់ពេលិឥឡូវខ្ញុំត្រូវការចិញ្ចឹងកូនដោះស្រាយខ្លួនឯងនិងធ្វើអីនិងតែម្នាក់ឯងអីអញ្ចឹងពិបាកក្នុងការធ្វើអីអញ្ចឹងទៅហើយមានកូននិងចំនួនបីនាក់ចិញ្ចឹមកូនបីនាក់ទាំងខ្លួនឯងទៅហើយអត់មានផ្ទះនិងដីសម្រាប់ខ្លួនឯងនិងគឺអត់មានទាំងអស់តែម្ដង។

ក៖ ចុះប្ដីរបស់មក?

ខ៖ គាត់អត់នៅទេ?

ក៖ គាត់ទៅណាដែលបង?

ខ៖ ពួកយើងនិងគឺបែបគ្នាហើយនិង។

ក៖
គួរអោយស្ដាយ?តើបងអាចប្រាប់ខ្ញុំបានទេបងថាតើបងឆ្លងកាត់ការលំបាកនិងយ៉ាងមិចដែលទៅបង?

ខ៖
ខ្ញុំចំពោះខ្ញុំជំនេះគ្រប់យ៉ាងទោះជាខ្ញុំនិងពិបាកប៉ុណ្ណាក៏ដោយក៏ខ្ញុំមិនខ្លាចដែលខ្ញុំនិងប្រឈមមុខជំនេះគ្រប់យ៉ាងដើម្បីអោយកូនបានរៀនអោយចេះដឹងកុំអោយវេនាដូចជាខ្ញុំហើយខ្ញុំ

បានរកឃើញអង្គការផ្តល់ជំនួយហើយបើខ្លួនខ្ញុំនិងមិនសូវឈឺវារៀងស្រួលបន្តិចសម្រាប់ខ្ញុំដែលរាល់ថ្ងៃនិងឈឺហើយរកលុយមកអោយកូនរៀនអីទៀតអត់មានបងប្អូនឪពុកម្តាយណាមកជួយបានទេឬក៏គ្មានអ្នកណាមកជួយខ្ញុំទេខ្ញុំជួយនិងធ្វើការដោះស្រាយនិងដោយខ្លួនខ្ញុំនិង។

ក៖
អរគុណច្រើនបងតើបងមានបទពិសោធន៍ល្អអ្វីខ្លះដែលបងដូចជាបទពិសោធន៍ដែលល្អៗ?

ខ៖
ពេលរកលុយបានអោយកូនទៅរៀនអីអញ្ចឹងទៅសប្បាយចិត្តមួយដែលកូនត្រូវគោលដៅមួយហើយហើយអង្គការបានជួយយើងទៅបានធូរ។

ក៖ អញ្ចឹងបងមានតែប៉ុហ្នឹងទេន៏បងបទពិសោធន៍ដែលល្អៗ?

ខ៖ ចានិងហើយ។

ក៖
ហើយក្តីសង្ឃឹមរបស់បងកាលពីក្មេងតើបងចង់ធ្វើជាអ្វីដែលបង?ដូចជាគ្រូបង្រៀនគ្រូពេទ្យគ្រូអីអញ្ចឹងបង?នៅពេលដែលបងនៅតូចអញ្ចឹងបង?

ខ៖
មានមានតាដូចជាខ្ញុំចង់ធ្វើជាគ្រូពេទ្យហើយខ្ញុំដូចជាមានដុងខាងនិងដែលតែគ្រាន់ថាខ្ញុំអត់មានអ្វីថាជួយជំរុញខ្ញុំចឹងអត់ចេះទៅ។

ក៖ ចាអញ្ចឹងតើបងមានអ្វីផ្តាំផ្ញើរដល់កូនចៅជំនាន់ក្រោយដែលទេបង?

ខ៖
ចង់ផ្តាំផ្ញើរដល់ក្មេងជំនាន់ក្រោយនិងអោយខិតខំរៀនសូត្រព្រោះឥលូវនិងមានគ្រូដែលល្អហើយមានសាលាដែលល្អរៀនមិនបាច់បង់ប្រាក់ក៏អាចរៀនបានដែលហើយអោយគាត់និងខិតខំក្នុងការយកចិត្តទុកដាក់ក្នុងការរៀនសូត្រដើម្បីកសាងជីវិតរបស់គាត់នៅក្នុងពេលអនាគត់។

ក៖ មានអ្វីបន្ថែមទៀតដែលទេបង?

ខ៖ ហើយក៏អរគុណខាងសកលវិទ្យាល័យ
ប៊ីវ៉ាយយូយកពាក្យទាំងអស់នេះទៅដល់កូនចៅជំនាន់ក្រៅបានរៀនបានស្គាល់និបបានដឹងផងដែលនិងបានស្គាលពីកាលលំបាករបស់អ្នកជំនាន់មុន។

កៈ ចាអរគុណបងច្រើនមែនទែនហើយខ្ញុំសូមថតរូបបងទុកជាអនុស្សាវរីផងបានទេបង?

ខៈ ថតទៅអត់អីទេ។

កៈ ចាអរគុណច្រើនបងបងជំរាបលាបង។